


រឿង

ទិព្វសង្វារ

ភាគ ១

TOEUP SANGVA

BW

Books World




សម័យមួយមានព្រះរាជាមួយអង្គ ទ្រង់ព្រះនាមត្រៃបុត្តី អគ្គមហេសីព្រះនាម ចន្ទរត្ថា សោយរាជ្យសម្បត្តិក្នុងនគរត្រៃបុរី តាំងនៅជិតព្រៃហិមពាន្ត។ ព្រះរាជា អង្គនេះទ្រង់មានឥទ្ធិពលយ៉ាងខ្លាំងក្លាក្រៃលែង មានស្តេចទាំង១០១នគរ ជាចំណុះ។ ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមព្រះភិរុណ។

Once upon a time there reigned a king named Trey Bottey with a queen named Chann Ratha at Tey Bottey kingdom close to the Himalayas. The king was so powerful that the kings of other 101 kingdoms were reduced to become his colonies. He had a son named Preah Phirun.




ថ្ងៃមួយ ព្រះមាតាទ្រង់នាំរាជកុមារទៅក្រសាលនៅមុខព្រះលាន ស្រាប់តែមានសត្វ
ឥន្ទ្រីហើរមកឆាបឆក់យករាជកុមារទៅដើម្បីធ្វើជាអាហាររបស់វា ប៉ុន្តែហេតុតែ
ភ័ព្វវាសនាល្អរបស់រាជកុមារ សត្វឥន្ទ្រីហើរទៅចំអាស្រមឥសី ឥសីឃើញសត្វឥន្ទ្រីពាំ
ព្រះរាជកុមារដូច្នេះក៏ស្រែកយ៉ាងខ្លាំងបំភ័យបង្អើលសត្វឥន្ទ្រី ។

One day the king brought along his son to relax in the royal court. Suddenly there appeared an eagle snatching the prince to use for its food. But because of his luck, while flying above a hermit's shrine, the hermit spotted the prince in the beast's beak and he shout very loudly to scare the eagle.








បក្សីភិតភ័យនឹងសម្រែកនោះ ក៏ទំលាក់ព្រះរាជកុមារចោលហើរយកតែខ្លួនទៅ ។ ឥសីវិលយកព្រះរាជកុមារទៅបង្ហាត់បង្រៀនមន្តវិជ្ជាចេះយ៉ាងស្ទាត់ជំនាញ។ ព្រះរាជកុមារនៅក្នុងសំណាក់ឥសីអស់១៥ឆ្នាំ ទើបលាឥសីត្រឡប់មកនគរវិញ ឥសីក៏ជប់សេះពាន រ និងធ្នូជ័យឱ្យ ហើយបង្ហាញផ្លូវឱ្យព្រះភិរុណទៅ។

Frightened, the bird dropped the prince and fled away. The hermit then picked up the prince and had him learning the magic skill. Having stayed in the hermitage for 15 years, the prince left the hermit and returned to the kingdom. Using the magic spell, the hermit created a horse, a monkey and a bow for the prince and showed Preah Phirun the way.



លុះធ្វើដំណើរដល់នគរកេតុជម្ពូ ព្រះភិរុណបានឃើញយក្សពិនរាជ និង វៃរតកំពុង ច្បាំងនិងនាងទិព្វសង្ខារ ក៏ទៅជួយច្បាំងនាងទិព្វសង្ខារ វាយពិនរាជ និងវៃរតស្លាប់។ នាងទិព្វសង្ខារ នាំព្រះភិរុណចូល ទៅក្នុងនគរកេតុជម្ពូ ដើម្បីទៅជួប និងព្រះមាតា ព្រះនាមផែសុមាលី ហើយទ្រង់ក៏រៀបអភិសេកព្រះភិរុណ និងនាងទិព្វសង្ខារ ឱ្យសោយ រាជ្យនគរកេតុជម្ពូ។

Arriving at the kingdom of Kettok Chumpu, the prince saw Giants Pinreach and Vayrat fighting with Teup Sangva, he then helped the princess to defeat and kill the two giants. Teup Sangva took Preah Phirun to her Kettok Chumpu kingdom to meet the queen, who then married the two and had the prince ruling the Kettok Chumpu kingdom.




ក្នុងរាត្រីដំបូងមានយក្សមួយឈ្មោះចិត្តនុរាជ ជាបងពិនរាជសោយរាជ្យក្នុងវិឆាយន្ត
ដោយខឹងនឹងព្រះភិរុណសម្លាប់ប្អូននិងក្មួយក៏មកសណ្តុំចាប់យកនាងទិព្វសង្ខារ
ទៅដាក់ទ្រុងដែកដើម្បីសម្លាប់ចោល ។

In the first night, there was a giant named Chetnureach, the brother of Pinreach, who reigned at Vichhayunn. Angry about the killing by Preah Phirun of his brother and cousin, he hypnotized and put Teup Sangva in the cage before having her killed.



ថ្ងៃងពីព្រះភិរុណ លុះព្រះអរុណោទ័យរះឡើង ពុំឃើញនាងទិព្វសង្ខារ ក៏ហៅសេនា
ទាំងបីមកប្រឹក្សា គន់គូរឃើញថាយក្សចិត្តនុរាជចាប់យកព្រះនាងទៅ ដោយបំណង
ថាប្រាំពីរថ្ងៃទៀតវានឹងសម្លាប់ ប៉ុន្តែមិនអីទេ បីថ្ងៃកន្លងផុតទៅ ព្រះអង្គនឹងជួប
ព្រះនាងវិញ។



When the sun rose, Preah Phirun did not see Teup Sangva. He got his three officers to consult and found out that she was seized by Chetnureach, who would kill her within 7 days. But after three days the prince would meet her.

ព្រះភិរុណក៏នាំសេនាចេញដំណើរទៅនគរវិឆាយន្ត ដើម្បីយកនាង
ទិព្វសង្ខារមកវិញ។ លុះទៅដល់ ក្នុងរាត្រីនោះ ព្រះភិរុណក៏សណ្តំយក្ស
ដេកលក់មិនដឹងខ្លួនសោះ ហើយ ចូលទៅក្នុងប្រាសាទគ្រប់ល្វែងបាន
ឃើញនាងសុគន្ធ ជាបុត្រីរបស់ចិត្តនុរាជ មានចិត្ត ប្រតិព័ទ្ធលួងលោម
ដោយសេចក្តីស្នេហា ដរាបបានសំរេចការដូចបំណង។

Preah Phirun took his soldiers to the kingdom of Vichhayunn to win back Teup Sangva. Upon arrival at the kingdom at night Preah Phirun hypnotized the giant and roamed all the rooms in the castle. The prince then saw Princess Sokunn, the daughter of Chetnureach. Falling in love. he did the courting and won her heart at last.






លុះពេលអរុណជិតរះ ព្រះភិរុណចេញពីបន្ទប់ទៅនាំនាងទិព្វសង្ខារចេញ
ពីក្រុងវិឆាយន្ត ត្រូវសំចតនៅលើភ្នំហាស្សភ័ណ្ឌ ដើម្បីរងចាំច្បាំងនិង
យក្ស។ ថ្លែងពីក្រុងចិត្តនុរាជ ភ្លឺឡើងពួកពលដែលយាមល្បាតមក
ក្រាបទូលថា នាងទិព្វសង្ខាររត់ចេញពីទ្រុងដែកបាត់ទៅហើយចិត្ត
នុរាជព្ញភ្លាមខឹងណាស់ ប្រើរាជអាមាត្រឱ្យទៅវាយស្គរប្រមូលកងទ័ព
ចេញទៅតាមនាងទិព្វសង្ខារ។


At dawn, Preah Phirun left the room and took Teup Sangva out of Vichhayunn capital. On the way, they stopped over on Horse Phorn mountain to prepare for war with the giant. Back in the kingdom, when the daybreak started, soldiers who guarded the cage came and told Chetnureach that Teup Sangva escaped. He was so furious that he had his servant to beat the drum to mobilized his troops to pursue Teup Sangva.

ក្នុងពេលនោះបក្សីវាយោភក្សជាកល្យាណមិត្តរបស់ចិត្តនុរាជ បានកេណ្ឌកងទ័ពទៅ
ជួយច្បាំងដែរ។ នៅក្នុងចម្បាំង ព្រះភិរុណនិងនាងទិព្វសង្ខារ បានសម្លាប់ចិត្តនុរាជ
និងវាយោភក្សព្រមទាំងពួកពលស្លាប់អស់ហើយចេញដំណើរទៅសំរាកកាយនៅខ្នង
ភ្នំមួយ ដោយនឿយហត់ខ្លាំងពេកក៏ផ្ទំលក់ទាំងសេះដែលនៅយាមប្រចាំការក៏លក់
ទាំងឈរដែរ។

At the time the bird Veayo Phek, the friend of Chetnureach, also mobilized its armies to help Chetnureach fight the war. During the fighting, Preah Phirun and Teup Sangva killed Chetnureach and Veayo Phek and all of their troops. The pair then set out to relax on a mountain.They were so exhausted that they felt asleep right away, and even the horse also slept while standing on guard.








គ្រានោះមានយក្សកុិណីម្នាក់ ឈ្មោះនីលភក្ត្រជាភរិយារបស់ចៅងោះ ដែលដើរទៅធ្លាក់ជ្រោះស្លាប់ នាងដើរទាំងសេចក្តីទុក្ខឡើងលើភ្នំ ឃើញព្រះភិរុណនិងនាងទិព្វសង្ខារកំពុងផ្ទំលក់ នឹកស្មានថានាងទិព្វសង្ខារជាប្រុសក៏ចាប់យកទៅបំរុងធ្វើជាប្តី។

There was a female giant named Nilphek, the wife of Chao Nhgos, who fell off and died in the deep valley. She was very sad. She climbed up the mountain and saw Preah Phirun and teup Sangva in their sound sleep. Mistaking Teup Sangva for a man, the female giant took her away and would have her as her husband.

ក្រោយពីភ្ញាក់ដឹងព្រះកាយឡើង ដឹងថាយក្សកុណីចាប់យកមកនាងទិព្វសង្ខារក៏សម្លាប់យក្សកុណីនោះស្លាប់ហើយដើរកាត់ដងព្រៃត្រឡប់មករកព្រះភិរុណវិញ។

Waking up and realizing that she was seized by the female giant, Teup Sangva killed the giant and walked through the forest to rejoin Preah Phirun.






នាងទិព្វសង្វារដើរវង្វេងក្នុងព្រៃទុគិម ដរាបបានបុត្រ១ឈ្មោះសុងសុិន ចូលទៅសុំ
សំណាក់នៅនិងឥសីដែលព្រះភិរុណធ្លាប់សំណាក់នៅនោះ ។

25 Lost in the Tukim forest, Teup Sangva gave birth to a son named Song Sinn. They met the hermit, with whom Preah Phirun once stayed, and asked the hermit to let them stay with him.

សូមរងចាំអានភាគ 2 ជាភាគបញ្ចប់




រឿង
ទឹកឮទេព្សាង
TEUP SANGVA
ភាគ ២
BW
Books World

លុះព្រះសុងសុិនមានវ័យចំរើនឡើង ក៏លាមាតាទៅតាមរកព្រះវរបិតា តែព្រះមាតាមិនព្រមបើកឱកាសឱ្យទៅសោះ។ ថ្ងៃមួយដោយនឹកព្រះវរបិតាខ្លាំងពេកទ្រាំនៅមិនបាន ក៏សរសេរសំបុត្រលាព្រះមាតានិងឥសីទុកនឹងកន្លែង ហើយចេញដំណើរទៅតាមរកព្រះវរបិតា និងទិព្វមន្ទារដែលយក្សលួចយកទៅនោះ។

When Prince Songsein grew up, he wanted to leave his mother in search of his father. But his mother did not give him the chance. One day as he could hardly wait to see his father, he decided to leave a message for his mother and his abbot teacher and set out to look for his father and Teup Montea, who was snatched by a giant



ក្នុងការធ្វើដំណើរទៅនោះ ព្រះរាជបុត្រសុងសុិនបានជួបនឹងព្រះភិរុណរាជជាព្រះអនុជ ក្នុងក្រុងកាមរាជ ជានគររបស់ព្រះរាជាសុីសុវិឆាយ អគ្គមហេសីឈ្មោះដាវតានិង បុត្រីឈ្មោះអំផៃភ័ក្ត្រ។ ក្នុងពេលនោះ ព្រះរាជកុមារទាំងពីរពុំស្គាល់គ្នាទៅវិញទៅ មកកើតច្បាំងគ្នារហូតដល់ ស្លាប់ពលអស់ ក៏សួរមាតាបិតាទៅវិញទៅមកទើបដឹង ថាជាបងប្អូននិងគ្នា ។

On the way, Prince Songsein met his brother, Prince Phirunn, in the capital of Kamreach, which was the kingdom of king Sisovichhay and queen Daodara, who got a daughter named Amphaiphek. The two princesses did not recognize each other. They fought until soldiers of both sides perished. They then came to know that they were nobody else other than siblings after having inquired about each other's parents.






ព្រះសុងសុិននិងសុីសុវិធាយរៀបចំអភិសេកព្រះនាងអំផៃភ័ក្ត្រ ឱ្យទៅជាអគ្គមហេសី
នៃព្រះអរុណរាជ មិនតែប៉ុណ្ណោះមានកើតចម្បាំងជាមួយនឹងយក្សជាច្រើនអន្លើទៀត
មានយក្សឈ្មោះកិនរាជដែលលួចយកនាងទិព្វមន្ទារជាដើម ប៉ុន្តែបាននាងសយសះ
សុីនិងយួនវិនិយាជួយ មានជ័យជំនះដរាបរហូតបានជួបនឹងព្រះភិរុណជាព្រះវរបិតា។
ចំនែកព្រះភិរុណ កាលបើព្រះអាទិត្យរះភ្លឺស្វាងតើនឡើង មិនឃើញនាងទិព្វសង្ខារ
ក៏នាំភិលៀងហោះរកនាងទិព្វសង្ខារ។



King Sisovichhay and Queen Daodara made Princess Amphaiphek the senior wife of Prince Ak-runreach, who fought many battlefields with giants, including Giant Kennreah, who stole Princess Teup Montea. Having been assisted by Saisaksi and Yuanviniyear, the prince won the war and was able to meet his father, Preas Phirunn. When the sun rose, Preas Phirunn woke up and did not see princess Teup Sangvar. Together with his servants, he flew around in search of the queen.






ដោយភ័ព្វអាក្រក់វង្វេងផ្លូវចូលទៅក្នុងនគរវិឆាយន្តឃើញយក្សឈ្មោះតុវេន្តរាជ
កំពុងតែច្បាំងជាមួយនឹងកងទ័ពវិឆាយន្តក៏ហោះចុះទៅក្នុងនគរវិឆាយន្តបានឃើញ
នាងឧប្បលវណ្ណា កំពុងតែយំសោកជាមួយនឹងនាងសុគន្ធព្រះធីតាសុមាលីជាបុត្រី ។

Unfortunately, he got lost and arrived at the kingdom of ViChha-yunn, where he saw Giant Tokvennareach battling with soldiers of Vichhay-yunn. He then lowered himself into Vichha-yunn kingdom and found Princess Oppalak-vanna and her daughter Sokunn Preas-phaisomali weeping.



ព្រះភិរុណលួងលោមព្រះនាងឱ្យឈប់យំសោកទ្រង់នឹងចេញច្បាំងយកអាសាថ្វាយ។ ទ្រង់ចេញច្បាំងជ័យជំនះ ហើយត្រឡប់ចូលមកក្នុងព្រះនគរវិញ ។ ព្រះនាងឧប្បលវណ្ណាក៏រៀបអភិសេកព្រះភិរុណនឹងនាងសុគន្ធព្រះផៃសុមាលីជាមហេសី គ្រងសម្បត្តិនគរវិឆាយន្ត។

Preas Phirunn tried to persuade them to stop crying and went to war in order to help them. He won victory and returned to the kingdom. Princess Oppalak-vanna married her daughter Sokunn Preas-phaisomali to Preas Phirunn and had him ascending the throne at ViChha-yunn kingdom.



នាងសុគន្ធព្រះផៃសុមាលីមានព្រះរាជបុត្រមួយអង្គឈ្មោះអរុណរាជ គ្រងរាជសម្បត្តិ
ក្រុងវិឆាយន្ត។ បន្ទាប់ពីពេលអភិសេកមក មានលែងល្បែងជាច្រើនមានកុន ល្ខោន
ជាដើម ព្រះភិរុណទតឃើញស្រីរបាំដែលតែងខ្លួនល្អហាក់ដូចស្រីទេពអប្សរ ក៏នឹក
ដល់នាងទិព្វសង្ហារជាអគ្គមហេសីទី១ហើយលានាងព្រះផៃសុមាលី ទៅតាមរក
នាងទិព្វសង្ហារ ដរាបបានជួបនឹងព្រះនាង ហើយនាំមកសោយរាជ្យក្នុងនគរកេតុដម្ព
ជានគររបស់បិតាព្រះនាងវិញ។

Queen Sokunn Preas-phaisomali had one son named Arunreach, who reigned at ViChha-yunn kingdom. During his reinstatement to the throne, many entertainment activities were put on. While watching the shows performed by beautiful dancers, King Preas Phirunn started to think of his first wife Teup Sangvar. He left Preas-phaisomali in search of Teup Sangvar. He found her and brought her back to and ruled at her father's kingdom, Ket-tokchumpou.



ព្រះភិរុណមានព្រះរាជបុត្រពីរ គឺព្រះសុងសុិនទឹងព្រះអរុណរាជ ព្រះអរុណមានអគ្គមហេសីមួយព្រះនាមអំផៃភក្ត្រ មានបុត្រីមួយឈ្មោះអំផាន់ណាវែត។ ព្រះសុងសុិនមានអគ្គមហេសី៥

១-ព្រះនាងទិព្វមន្ទារ មានព្រះរាជបុត្រ១ឈ្មោះសុរិយាវង្ស

២-ព្រះនាងសយមណី មានព្រះរាជបុត្រី១ឈ្មោះមាលាវ៉ណ្ណ

៣-ព្រះនាងទេពអប្សរ មានព្រះរាជបុត្រ១ឈ្មោះសុងសុិនធព្វ

៤-យួនវិនិយា

៥-សយសះសី

បណ្តាបុត្រាបុត្រីទាំងនោះ ព្រះសុងសុិនធព្វជាព្រះរាជបុត្រយ៉ាងជំនាញក្នុងសឹកសង្គ្រាម បានច្បាំងនឹងនរិន្ទមាត្រ។

Preas Phirunn got two sons- Princes Songsein and Arunreach. Prince Arunn was married to Princess Amphai-phek, and they gave birth to a daughter named Amphann Navet. Prince Song Sein was married to 5 princesses:

1- Princess Teup Montea got a son named Soryavong

2- Princess Sai Mani got a daughter named Mealea Vann

3- Princess Tep Apsar got a son called Songsein Thop

4- Yuanviniyear

5- Soysassei

Among those sons and daughter, Prince Songsein Thop was very skilful in the battlefield. He fought with No-rinmeat.



នរិន្ទមាត្រចុះចាញ់ថ្វាយនគរវេឡុវននឹងបុត្រីឱ្យជាអគ្គមហេសីសោយរាជ្យក្នុងនគរនោះ ហើយជូនដំណើរព្រះសុងសុិនធព្វទៅក្រុងត្រៃបុរី ដើម្បីជួបព្រះអយ្យកាអយ្យកោ។


No-rinmeat surrendered, conceding Veilokvonn kingdom and marrying his daughter to Prince Songsein Thop, who then became the king of the territory. He accompanied Prince Songsein Thop on the way to Traiborey to meet his grand parents.





ព្រះអយ្យកោ អយ្យកា កាលបើឃើញចៅហើយមានសេចក្តីសោមនស្សត្រេកអរជាពន់ពេក ហើយនាំព្រះនត្តាទៅក្រុងវិឆាយន្តដើម្បីជួបព្រះសុងសុិនជាព្រះវរបិតាទៀត។ នរិន្ទមាត្រ នៅក្នុងទីនោះអស់៧ថ្ងៃ ក៏សុំលាដន្លងនាំសុងសុិនធព្វមកក្រុងវេឡុវនវិញ។

The grand parents were very excited to see their grand children, and brought them to the city of Vicha-yuon to meet their father, Songsein. After spending 7 days there, No-rinmeat left his in-laws and returned to the city of Velokvorn with Songsein-Thop.





ផ្លែងពីព្រះចន្ទឋិននៅឋានសួគ៌មានព្រះរាជបុត្រពីរអង្គ ដេដ្ឋបុត្រឈ្មោះចន្ទកិរិយា អនុបុត្រឈ្មោះកិរិយាចន្ទ។ លុះបុត្រទាំងពីរមានវ័យចំរើនឡើង ទៅដណ្តឹងនាង មាលាវណ្ណជាបុត្រីព្រះសុងសុិនឱ្យចន្ទកិរិយាអភិសេកឱ្យសោយរាជ្យនគរពេជ្រ រត្នរម្យសីមា។ ទៅដណ្តឹងនាងអំផាន់ណាវេតជាបុត្រីព្រះអរុណរាជ ឱ្យកិរិយាច័ន្ទអភិ សេកឱ្យសោយរាជ្យនគររដ្ឋរាជ ។

Preas Chann in heaven had two sons- the elder named Channke-rya, and the young named Ke-ryachann. When the two grew up, the father went to ask for the hands of Princess Mealeavann, the daughter of King Preas Songsein, for Channke-rya, who after the marriage, reigned at Pechrothrom-seima. He asked King Arunreach to marry his daughter Amphannaveth to Prince Ke-ryachann, who became king of Rothreach kingdom.

ព្រះសុងសុិនកាលបើរៀបអាវាហវិវាហមង្គល បុត្រីនិងក្មួយស្រីរួចហើយក៏និយាយ
និងព្រះចន្ទជាដន្លងថា ខ្ញុំនៅសល់បុត្រម្នាក់ឈ្មោះសុរិយាវង្សសព្វថ្ងៃនៅជាមួយ
នឹងសុងសុិនធព្ធ ជាកូនបងឯនោះ ហើយពុំទាន់មានអគ្គមហេសីនៅឡើយ ។

After the marriages of his daughter and niece, King Songsein said to his in-law, Preas Chann : "I still have one more son, Soryavong, who has been living with the elder son, Songsein Thop. He is still single".





ព្រះចន្ទតបថា បើដូច្នោះ យើងនឹងទៅដណ្តឹងនាងកែវសុវណ្ណជាបុត្រីព្រះនារាយណ៍ឱ្យ
ព្រះសុរិយាវង្ស ។ ព្រះសុងសុិនក៏យល់ព្រមហើយនាំគ្នារៀបគ្រឿងបណ្ណាការចូរទៅ
គំនាប់គាប់គូរព្រះនារាយណ៍ដើម្បីដណ្តឹងបុត្រី ។ ព្រះនារាយណ៍ក៏យល់ព្រមឱ្យហើយ
រៀបចំអភិសេកព្រះសុរិយាវង្ស និងនាងកែវសុវណ្ណឱ្យសោយរាជ្យនគរសុវណ្ណមាលី ។

Preas Chann replied: "So I will ask Vishnu to marry his daughter Keo Sovann to Prince Soryavong. King Songsein agreed to the idea, and with dowries, they came to pay courtesy call on Vishnu, who had no objection. Prince Soryavong and Princess Keo Sovann got married, with the prince ascending the throne at Sovannmealea kingdom.

ចប់

The End

